**សិក្ខាសាលាចាប់ផ្តើមការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និង**
**ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ**
**ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣**
**សណ្ឋាគារ ហ៊ីម៉ាវ៉ារី ភ្នំពេញ កម្ពុជា**

# សុន្ទរកថាបើកសិក្ខាសាលារបស់ឯកឧត្តម ធឹក គ្រឿនវុត្ថា រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាតំណាងឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រធានគណៈកម្មាធិការជាតគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

*សូមគោរព*

- *ឯកឧត្តម នុត ច័ន្ទសុខា អនុរដ្ឋលេខាធិការក្រសួងផែនការ សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ*
- *ឯកឧត្តម ហ្សង់ ហ្វ្រង់ស្វ័រ កូតាំង ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ*
- *លោក លោកស្រី ជាតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ជាទីមេត្រី*

ថ្ងៃនេះខ្ញុំមានកិត្តិយស និង សេចក្តីរីករាយយ៉ាងខ្លាំង ដែលបានមកចូលរួមជាគណៈអធិបតីនៅក្នុងពិធីប្រកាសបើកសិក្ខាសាលាចាប់ផ្តើមការរៀបចំក្របខណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅកម្ពុជា។ ជួសមុខឲ្យ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសិក្ខាកាមទាំងអស់ ដែលបានអញ្ជើញមកចូលរួមនៅក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ការប្រែប្រួលអាកាសធាតុ ថាជាបញ្ហាគន្លឹះដែលត្រូវដោះស្រាយ ដើម្បីអភិវឌ្ឍន៍ប្រទេសដោយចីរភាព។ ក្នុងន័យនេះ ការប្រែប្រួលអាកាសធាតុ ត្រូវបានចាត់ទុកថាជា បញ្ហាសំខាន់មួយ ក្នុងចំណោមបញ្ហាអន្តរវិស័យនានា ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨។

ក្នុងរយៈពេល ១២ ខែកន្លងមកនេះ សមាជិកទាំងអស់នៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ បានរួមចំណែកយ៉ាងសកម្ម ក្នុងការកសាងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែលឥឡូវនេះស្ថិតនៅក្នុងដំណាក់កាលរៀបចំបញ្ចប់ មុននឹង អនុម័តជាផ្លូវការ។ នេះគឺជាដំណើរការមួយ ដែលបានឆ្លងកាត់ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ។ តាមរយៈការគាំទ្រពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងអាទិភាពចំនួនប្រាំបួនបានធ្វើការយ៉ាងសកម្ម ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ខ្លួន ដោយបានបន្សុីគ្នាជាមួយផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ។

ដូចនៅក្នុងដំណើរការកសាងផែនការដទៃទៀតផងដែរ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងយុទ្ធសាស្ត្រតាមវិស័យ ពុំមានភាពពេញលេញឡើយ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ប្រសិនបើគ្មានផែនការសកម្មភាព ដែលចែងអំពីក្របខ័ណ្ឌសម្រាប់ប្រតិបត្តិការយុទ្ធសាស្ត្រនេះ។ ដូច្នេះ ការកសាងផែនការសកម្មភាពគឺជាជំហានបន្ទាប់ នៅក្នុងដំណើរការនេះ ដែលនឹងនាំទៅរកការអនុវត្តសកម្មភាពសំខាន់ៗ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

ការពិនិត្យលើការចំណាយក្នុងវិស័យសាធារណៈ និងស្ថាប័នសម្រាប់ការប្រែប្រួលអាកាសធាតុ នៅឆ្នាំ ២០១២ បានបង្ហាញថា បណ្តាសក ម្មភាពដែលទាក់ទងនឹងអាកាសធាតុនៅក្នុងវិស័យជាច្រើន បានទទួលរួចមកហើយនូវការគាំទ្រមូលនិធិ ពីប្រភពក្នុងប្រទេស និងពីអន្តរជាតិ។ ការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្មីមួយនេះនឹងអាចឲ្យយើងបង្កើនប្រសិទ្ធភាពនៃការចំណាយបច្ចុប្បន្នរបស់យើង នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបង្កើតវិធីសាស្ត្រថ្មីៗ សម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឲ្យបានកាន់តែប្រសើរជាងមុន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ជាមួយវដ្តថ្មីនៃការកសាងផែនការរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំ ២០១៤ ឥឡូវនេះគឺជាពេលដែលត្រូវអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងក្រសួងពាក់ព័ន្ធនានា។ ថ្ងៃនេះយើងជួបជុំគ្នា ដើម្បីប្រកាសចាប់ផ្តើមកិច្ចការសំខាន់ៗផុតចំនួនពីរគឺ ៖

- ទីមួយគឺការកសាងផែនការសកម្មភាពថ្នាក់ក្រសួងសម្រាប់រយៈពេលប្រាំឆ្នាំខាងមុខ ដែលនឹងបង្ហាញនិងចាត់ជាអាទិភាពនូវសកម្មភាពលំអិតនានា សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ។ ផែនការសកម្មភាពទាំងនេះនឹងរួមបញ្ចូលផងដែរនូវព័ត៌មានអំពីវិធីក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការហិរញ្ញប្បទាន និងនីតិវិធីអនុវត្តរបស់ក្រសួងនានា។
- កិច្ចការទីពីរគឺការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ ក្របខ័ណ្ឌហិរញ្ញប្បទាននេះនឹងមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយផែនការសកម្មភាព ដោយសារថា វានឹងផ្តល់ព័ត៌មានអំពីសេណារីយ៉ូហិរញ្ញប្បទាន, ថ្លៃចំណាយសម្រាប់អនុវត្តវិធានការឆ្លើយតបដែលស្នើឡើង, ផលប្រយោជន៍រំពឹងទុក ព្រមទាំងអនុសាសន៍នានាស្តីពីហិរញ្ញប្បទាន និងយន្តការសម្របសម្រួល។

រួមជាមួយគ្នា កិច្ចការទាំងពីរនេះនឹងរួមចំណែកបង្កើតឲ្យមានក្របខ័ណ្ឌមួយប្រកបដោយតម្លាភាព ដែលអាចទុកចិត្តបាន និងមានភាពទាក់ទាញ សម្រាប់ការផ្តល់ហិរញ្ញប្បទានដល់វិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ផែនការសកម្មភាពនឹងតំណាងឲ្យដំណើរការមួយ ដែលមានបែបផែនជាការចូលរួម ហើយ ដែលអ្នកពាក់ព័ន្ធនានាចូលរួមផ្តល់គំនិតជាក់លាក់ ដើម្បីបង្កើតជាវិធានការសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ ផែនការសកម្មភាពទាំងនេះគួរតែមានមហិច្ឆិតាខ្ពស់ ប៉ុន្តែមានភាពជាក់ស្តែង ទន្ទឹមនឹងការគិតគូរផងដែរអំពីតថភាពខាងហិរញ្ញវត្ថុ។ ការវិភាគអំពីហានិភ័យអាកាសធាតុបច្ចុប្បន្ន និងអនាគត ក៏ដូចជានិន្នាការនៃហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នឹងត្រូវធ្វើឡើងផងដែរ ដោយប្រើប្រាស់សេណារីយ៉ូមួយចំនួន ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ចាត់ជាអាទិភាពនូវសកម្មភាពនានា ដែលលើកស្នើឡើង។

ផែនការសកម្មភាពទាំងនេះក៏នឹងពិនិត្យមើលផងដែរនូវវិធីជាក់លាក់នានា ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងទម្លាប់ប្រតិបត្តិគ្រប់គ្រងជាប្រក្រតីរបស់រាជរដ្ឋាភិបាល ដូចជាការកសាងផែនការ, យន្តការហិរញ្ញប្បទាន ដែលរួមទាំងដំណើរការលើកថវិកា, ការពិនិត្យតាមដាន និងវាយតម្លៃ ព្រមទាំង ផ្តល់ជាការណែនាំ សម្រាប់ការបង្កើតមេរៀនដែលផ្អែកលើភស្តុតាង សម្រាប់ជាមូលដ្ឋាននៃដំណើរការធ្វើសេចក្តីសម្រេច។

កិច្ចការកសាងផែនការសកម្មភាពមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ។ គោលដៅរួមគឺការបង្កើតឲ្យមានសកម្មភាពឆ្លើយតបចម្រុះសំខាន់ៗ និងការកំណត់ថ្លៃចំណាយ ដែលធ្វើឲ្យផែនការទាំងនោះមានភាពទាក់ទាញ អាចទុកចិត្តបាន និងមានតម្លាភាព តាមរបៀបមួយដែលអាចបញ្ចូលហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុដែលមានប្រភពក្នុងស្រុក និងពីអន្តរជាតិ ដោយងាយស្រួល និងអាចតាមដានបាន នៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ជាតិ។

វិធីសាស្ត្រជាយុទ្ធសាស្ត្រនេះមានលក្ខណៈច្នៃប្រឌិតខ្ពស់។ យើងព្យាយាមងាកចេញពីវិធីសាស្ត្រដែលផ្អែកសុទ្ធសាធតែលើគម្រោង និងរួមបញ្ចូលពិតប្រាកដនូវការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការវិនិយោគ និងការធ្វើសេចក្តីសម្រេចជាប្រក្រតី ដោយប្រើប្រាស់អភិក្រមកម្មវិធី។

ក្រសួងពាក់ព័ន្ធជាអាទិភាពមានតួនាទីដ៏សំខាន់នៅក្នុងកិច្ចការនេះ។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងសមាជិកក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ មានភារៈផ្តល់ការណែនាំខាងគោលនយោបាយ ការសម្របសម្រួល និងការ គាំទ្របច្ចេកទេស ក៏ ប៉ុន្តែតួនាទីអនុវត្តគឺជាភារៈកិច្ចរបស់ក្រសួងពាក់ព័ន្ធ។ ដើម្បីគាំទ្រក្រសួងទាំងនេះ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្រសួងបរិស្ថាន ដោយមានការគាំទ្រពីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា និងម្ចាស់ជំនួយនៃសម្ព័ន្ធភាពនេះ ពោលគឺដានីដា ស៊ីដា សហភាពអឺរ៉ុប និងយូអឹនឌីភី នឹងផ្តល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងនីមួយៗ។ សូមថ្លែងអំណរគុណជាពិសេសដល់ស៊ីដា ដែលបានផ្តល់វិភាជន៍ធនធានថែមទៀតពីថ្នាក់តំបន់ ដើម្បីគាំទ្រដល់ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នៅកម្ពុជា។

ខ្ញុំសូមអបអរសាទរចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានផ្តល់កិច្ចសហការយ៉ាងល្អប្រសើរ រហូតមកដល់ពេលនេះ ទាំងក្នុងចំណោមក្រសួង និងជាមួយដៃគូក្រៅប្រទេសរបស់យើង។ ខ្ញុំសង្ឃឹមថាសិក្ខាសាលានេះនឹងផ្តល់ឲ្យអ្នកពាក់ព័ន្ធទាំងអស់នូវព័ត៌មានចាំបាច់ ដើម្បីរួមចំណែកក្នុងការកសាងផែនការសកម្មភាព និងក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ នៅក្នុងរយៈពេលបីខែខាងមុខនេះ ហើយយើងត្រៀមខ្លួនឲ្យរួចជាស្រេចដើម្បីចាប់ផ្តើមអនុវត្តកម្មវិធីប្រកបដោយមហិច្ឆិតានេះនៅចុងឆ្នាំនេះ។ សូមអរគុណជាថ្មីម្តងទៀតចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ តំណាងក្រសួង -ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកអង្គសិក្ខាសាលាទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងផ្តល់ការគាំទ្រដោយឥតសំចៃ ដល់កិច្ចខិតខំរបស់យើងទាំងអស់គ្នា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ខ្ញុំសូមជូនពរឲ្យអង្គសិក្ខាសាលាប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងសូមប្រកាសបើកសិក្ខាសាលា ចាប់ពីពេលនេះតទៅ។

សូមអរគុណ !